00527478

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 08 / 06 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

A372/2/7

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

តាងនាមប្រជារាស្ត្រខ្មែរ និងតាងនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 08 / 06 / 2010
ម៉ោង (Time/Heure): 11:50
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០២/០៧-១២-២០០៧-អវតក/អបជ(៦៥)

ចំពោះមុខ:
ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម នៃ ថុល
ចៅក្រម Catherine MARCHI-UHEL
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ: ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១០

---

**សាធារណៈ:**

**សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាបដិសេធរបស់ ក.ស.ច.ស ទៅនឹងសំណើលើកទីបី សុំឲ្យផ្តល់ជូនមេធាវីការពារក្តីនូវតារាងវិភាគពីភស្តុតាងជាមួយនឹងដីកាដំណោះស្រាយ**

---

**សហព្រះរាជអាជ្ញា**
ជា លាង
Andrew CAYLEY

**ជនត្រូវចោទ**
អៀង សារី

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
នី ចាន់ឌី
Mahdev MOHAN
Lyma NGUYEN
គឹម ម៉េងឃី
ម៉ុច សុវណ្ណារី

**សហមេធាវីការពារក្តី អៀង សារី**
អាង ឧត្តម
Michael G. KARNAVAS

អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * E.C.C.C * C.E.T.C

00527479

Elizabeth-Joelle RABESANRATANA
Annie DELAHAIE
Philippe CANONNE
Martine JACQUIN
Fabienne TRUSSES-NAPROUS
Françoise GAUTRY
Issabelle DURAND
Christine MARTINEAU
Laure DESFORGES
Ferdinand DJAMMEN
ឡោ ជុនធី
ស៊ីន សុវ៉ន
សំ សុគង់
ហុង គឹមសួន
គង់ ពិសី
គង់ ហេង
Ms. Silke STUDZINSKY
Mr. Olivier BAHOUGNE
Ms. Marie GUIRAUD
Mr. Patrick BAUDOUIN
ជេត វណ្ណលី
ពេជ អង្គ
Julien RIVET
Pascal AUBOIN
យុង ផានិត

**សហចៅក្រមស៊ើបអង្កេត**
ចៅក្រម យូ ប៊ុនឡេង
ចៅក្រម Marcel Lemonde

**ដើមបណ្តឹងរដ្ឋប្បវេណីគ្មានមេធាវីតំណាង**

ANGKOR BUREAU DES CHAMBRES PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

00527480



**អង្គបុរេជំនុំជម្រះ**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“**អ.វ.ត.ក**”) បានទទួលបណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តីលោក **អៀង សារី** (“ជនត្រូវចោទ”) ប្រឆាំងនឹងដីកាបដិសេធរបស់ ក.ស.ច.ស ទៅនឹងសំណើលើកទីបីរបស់អៀងសារី សុំឱ្យផ្តល់ជូនមេធាវីការពារក្តីនូវតារាងវិភាគពីភស្តុតាងជាមួយនឹងដីកាដំណោះស្រាយ ដែលបានដាក់ និងជូនដំណឹងនៅ ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១០ (“បណ្តឹងឧទ្ធរណ៍”)[១]។ ចម្លើយតបរបស់សហចៅក្រមស៊ើបអង្កេតចំពោះសំណើរបស់ អៀង សារី សុំឱ្យផ្តល់ជូនមេធាវីការពារក្តីនូវតារាងវិភាគពីភស្តុតាង ត្រូវបានចុះកាលបរិច្ឆេទថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១០ និងត្រូវបានជូនដំណឹងនៅថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១០ (“ដីកា”)[២]។ សំណើសុំរបស់ អៀង សារី លើកទីបី ត្រូវបានដាក់កាលបរិច្ឆេទ និងជូនដំណឹងនៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១០ (“សំណើសុំ”)[៣]។ សហព្រះរាជអាជ្ញាបានដាក់ចម្លើយតបមួយនៅថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១០ ដែលត្រូវបានជូនដំណឹងនៅថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១០ ដោយបានស្នើសុំឱ្យអង្គបុរេជំនុំជម្រះបដិសេធបណ្តឹងឧទ្ធរណ៍នេះចោល ដោយហេតុថា “វាបានរារាំងដល់ដំណើរការនីតិវិធី និងមានការយល់ខុសយ៉ាងខ្លាំង”[៤]។ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះធ្វើការសម្រេចលើបណ្តឹងឧទ្ធរណ៍

---

[១] បណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងទៅនឹងការបដិសេធរបស់ ក.ស.ច.ស ចំពោះសំណើសុំឱ្យផ្តល់ជូនមេធាវីការពារក្តីនូវតារាងវិភាគពីភស្តុតាងជាមួយនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១០ សំណុំរឿង ០០២/១៩-០៩-២០០៧/អវតក/កសចស (អបជ ៦៥) ឯកសារ A371(sic)/2/1។

[២] ចម្លើយតបរបស់សហចៅក្រមស៊ើបអង្កេតចំពោះសំណើរបស់ អៀង សារី សុំឱ្យផ្តល់ជូនមេធាវីការពារក្តីនូវតារាងវិភាគពីភស្តុតាង ត្រូវបានចុះកាលបរិច្ឆេទថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១០ និងត្រូវបានជូនដំណឹងនៅថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១០ សំណុំរឿង ០០២/១៩-០៩-២០០៧/អវតក/កសចស - A372 ឯកសារ A372/1។

[៣] សំណើរបស់ លោក អៀង សារី ស្នើសុំតារាងវិភាគដែលភ្ជាប់ទំនាក់ទំនងរវាងអង្គហេតុនីមួយៗជាមួយភស្តុតាងដាក់បន្ទុក ឬភស្តុតាងដោះបន្ទុកនីមួយៗ និងជាមួយនឹងធាតុផ្សំនីមួយៗនៃបទល្មើសដែលត្រូវចោទប្រកាន់ និងជាមួយធាតុផ្សំនីមួយៗដែលបង្កើតជាទម្រង់នៃការចូលរួមប្រព្រឹត្តដែលជាផ្នែកមួយនៃដីកាដំណោះស្រាយ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១០ សំណុំរឿង ០០២/១៩-០៩-២០០៧/អវតក/កសចស ឯកសារ A372។

[៤] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី យោង: ការសុំឱ្យផ្តល់ជូននូវតារាងវិភាគភស្តុតាងជាមួយនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១០ សំណុំរឿង ០០២/១៩-០៩-២០០៧/អវតក/កសចស(អបជ ៦៥) ឯកសារ A372/2/2 កថាខណ្ឌទី៦។

00527481



ដោយផ្អែកលើសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ និងសេចក្ដីណែនាំពាក់ព័ន្ធនឹងការដាក់សារណាតប[៥] សហមេធាវីការពារក្ដីបានដាក់សារណាតប នៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១០[៦]។

*ភាពអាចទទួលយកបាននៃបណ្ដឹងឧទ្ធរណ៍*

១. បណ្ដឹងឧទ្ធរណ៍ត្រូវបានដាក់ទាន់ពេលវេលាផ្អែកតាមវិធាននៃផ្ទៃក្នុង។

២. មិនមានមូលដ្ឋានសម្រាប់បណ្ដឹងឧទ្ធរណ៍ទេ។ ដោយមិនគិតថា ការបដិសេធនោះមានចរិតលក្ខណៈដូចម្ដេចនោះទេ វាមិនមែនជាសេចក្ដីសម្រេចដែលអាចប្ដឹងឧទ្ធរណ៍បានទេ។ សំណើសុំ គឺទាក់ទងនឹងកិច្ចស៊ើបសួរនាពេលអនាគត ដែលអាចត្រូវបំពេញ ឬមិនត្រូវបំពេញដោយសហចៅក្រមស៊ើបអង្កេត។ សំណើសុំមានបំណងដាក់កម្រិត និងគ្រប់គ្រងលើវិធី និងទម្រង់ដែលសហចៅក្រមស៊ើបអង្កេតអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន។ ចេតនាបែបនេះបានបញ្ជាក់ច្បាស់នៅក្នុងបុព្វបទនៃសំណើសុំ និងការស្នើសុំជាក់លាក់ ដែលមាននៅក្នុងសេចក្ដីសន្និដ្ឋាននៃសំណើសុំ។

៣. បុព្វបទនៃសំណើបានលើកឡើងថា៖

> "លោក អៀង សារី តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារក្ដី") អនុលោមតាមវិធាន៦៧ និងវិធាន២១(១)(ឃ) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក តទៅនេះ សូមស្នើសុំតារាងវិភាគ ដោយសារតែជាផ្នែកមួយនៃដីកាដំណោះស្រាយ ដែលភ្ជាប់ទំនាក់ទំនងរវាងអង្គហេតុនីមួយៗជាមួយភស្តុតាងដាក់បន្ទុក ឬដោះបន្ទុកនីមួយៗដែលពាក់ព័ន្ធ ព្រមជាមួយធាតុផ្សំ

PRE-TRIAL CHAMBER E.C.C.C * C.E.T.C CHAMBRE PRÉLIMINAIRE

[៥] សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ដោយផ្អែកលើសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ និងសេចក្ដីណែនាំឲ្យធ្វើការឆ្លើយតប ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១០ សំណុំរឿង ០០២/១៩-០៩-២០០៧/អវតក/កសចស (អបជ ៦៥) ឯកសារ A372/2/4។

[៦] សារណាតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្ដឹងឧទ្ធរណ៍របស់សហមេធាវីការពារក្ដីប្រឆាំងនឹងសេចក្ដីសម្រេចរបស់ ក.ស.ច.ស ដែលបានបដិសេធសំណើរបស់សហមេធាវីការពារក្ដីសុំឲ្យផ្ដល់នូវតារាងវិភាគពីភស្តុតាងជាមួយនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១០ សំណុំរឿង ០០២/១៩-០៩-២០០៧/អវតក/កសចស (អបជ ៦៥) ឯកសារ A372/2/5។

នីមួយៗនៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ និងធាតុផ្សំនីមួយៗដែលបង្កើតជាទម្រង់នៃការចូលរួមប្រព្រឹត្ត នៅក្នុងករណីដែល ក.ស.ច.ស ពិចារណាបញ្ជូនលោក អៀង សារី ទៅជំនុំជម្រះចំពោះអង្គហេតុទាំងអស់ ឬអង្គហេតុមួយចំនួន ដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម”។

៤. សំណើសុំនេះមិនស្ថិតនៅក្រោមបទប្បញ្ញត្តិវិធាន៥៥(១០)នៃវិធានផ្ទៃក្នុង ដោយសារតែសំណើនេះមិនបានស្នើសុំឲ្យចេញដីកា ឬបំពេញកិច្ចស៊ើបសួរណាមួយទេ។ វិធាន២១(១)(ឃ)នៃវិធានផ្ទៃក្នុង មិនមានចែងអំពីសិទ្ធិណាមួយ ឬការបកស្រាយតាមរូបភាពណាមួយ ដែលអាចផ្តល់នូវមូលដ្ឋាន សម្រាប់ប្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធរបស់សហចៅក្រមស៊ើបអង្កេត ដើម្បីឲ្យសហចៅក្រមស៊ើបអង្កេតពិចារណាលើសំណើ ដែលអាចពាក់ព័ន្ធទៅនឹងការអនុវត្តគន្ទានុសិទ្ធិដែលនឹងអាចកើតមានឡើង។ បណ្តឹងឧទ្ធរណ៍មិនអាចទទួលយកបានតាមទម្រង់ ដូចនេះអង្គបុរេជំនុំជម្រះមិនចាំបាច់ពិចារណាសារណាបន្ថែមទៀតនោះទេ។

**ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆ័ន្ទ÷**

បណ្តឹងឧទ្ធរណ៍នេះ មិនអាចទទួលយកបាន។

ដោយអនុលោមតាមវិធាន៧៧(១៣) នៃវិធានផ្ទៃក្នុង សាលដីកានេះត្រូវបិទផ្លូវតវ៉ា។

**ភ្នំពេញ ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១០**

**ចៅក្រមអង្គបុរេជំនុំជម្រះ**

Rowan DOWNING **ន៉យ ថុល** Catherine MARCHI-UHEL **ហួត ធុទ្ធិ** **ប្រាក់ គិមសាន**